ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ៖ ០៧៧/១៧ ....ស.ស.រ

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ ធ្នូ ឆ្នាំ២០១៧

# សេចក្តីសម្រេច
# ស្តីពី
# ការប្រគល់ភារកិច្ច

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
## និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញអនុក្រឹត្យលេខ ២៧៣អនក្រ.បក ចុះថ្ងៃទី ០៧ ខែតុលា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញអនុក្រឹត្យលេខ ១០៩អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញសេចក្តីសម្រេចលេខ ១៤៥សសរ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០១៤ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- យោងតាមការចាំបាច់

## <u>សម្រេច</u>

**ប្រការ១** : ប្រគល់ភារកិច្ចជូនលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) ដើម្បីដឹកនាំការងារគ្រប់គ្រងលំហូរពលករទេសន្តរប្រវេសន៍មិនប្រក្រតីតាមព្រំដែននៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២** : អំពីតួនាទី និងភារកិច្ច ៖

- បង្កើតក្រុមការងារ ដើម្បីសិក្សាស្រាវជ្រាវអំពីស្ថានភាពលំហូរពលករទេសន្តរប្រវេសន៍មិនប្រក្រតី និងសិក្សាអំពីផលប៉ះពាល់នៃការបិទច្រករបៀង
- ដឹកនាំការប្រជុំរៀបចំគោលនយោបាយ និងវិធានការគ្រប់គ្រងលំហូរពលករទេសន្តរប្រវេសន៍
- ធ្វើរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីស្នើសុំអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់។

**ប្រការ៣** : ឯកឧត្តម លោកជំទាវ ជាប្រធានក្រុមការងារជំនាញអន្តរក្រសួងស្ថាប័នទាំង ០៦ របស់ គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិកា គ.ជ.ប.ជ អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម

ប្រធានក្រុមប្រឹក្សានីតិកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ឯកឧត្តមប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងលោកជំទាវ **ជូ ប៊ុនអេង** ត្រូវសហការ ដើម្បីអនុវត្តសេចក្ដីសម្រេចនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

**សម្ដេចក្រឡាហោម ស ខេង**

*__កន្លែងទទួល៖__*

- *ក្រុមការងារជំនាញអន្តរក្រសួង-ស្ថាប័នទាំង០៦ របស់ គ.ជ.ប.ជ*
- *ខុទ្ទកាល័យ សម្ដេចក្រឡាហោម ស ខេង*
- *អគ្គស្នងការដ្ឋាននគរបាលជាតិ*
- *អគ្គនាយកដ្ឋានអន្តោប្រវេសន៍*
- *អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម*
- *អគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ*
- *ក្រុមប្រឹក្សានីតិកម្ម*
- *អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ*
- *ទីចាត់ការការងារព្រំដែននៃអគ្គបញ្ជាការដ្ឋានក្រសួងការពារជាតិ*
- *អភិបាលរាជធានី-ខេត្ត*
- *ដូចប្រការ៣*
- *ឯកសារ-កាលប្បវត្តិ*